មហិច្ឆិតាគណិតវិទ្យា

Maths Ambition

រៀបរៀងដោយ ឃន វ៉ាន់នី

៨២ លំហាត់និងដំណោះស្រាយ

$$1 = 1^2$$

$$1 + 3 = 2^2$$

$$1 + 3 + 5 = 3^2$$

$$1 + 3 + 5 + 7 = 4^2$$

$$1 + 3 + 5 + 7 + 9 = 5^2$$

$$1 + 3 + 5 + 7 + 9 + 11 = 6^2$$

$$1 + 3 + 5 + 7 + 9 + 11 + 13 = 7^2$$

$$1 + 3 + 5 + 7 + 9 + 11 + 13 + 15 + 17 = 8^2$$

....

....

$$1 + 3 + 5 + 7 + \ldots\ldots\ldots\ldots + (2n - 1) + (2n + 1) = (n + 1)^2$$

2011 Khon Vanny

សមាគម៍សាមគ្គីភាពបារាំង

ASSOCIATION FRANCAISE DE SOLIDARITE

(A F S)

រៀបរៀងដោយ

យន វ៉ាន់នី

ត្រួតពិនិត្យដោយ

លោក យ៉ង់ ឆារី (អនុបណ្ឌិត គណិតវិទ្យា)

លោក លឹម ផល្គុន (បរិញ្ញាប័ត្រ គណិតវិទ្យា)

ខ្ញុំសូមអរគុណដល់ ÷

+ អ្នកមានគុណទាំងពីរ ដែលបាន ផ្តល់កំលាំងចិត្ត និង ឧបត្ថម្ភដល់ការសិក្សា

+សមាគមន៍សាមគ្គីភាពបារាំង **(AFS)** ដែលបានផ្តល់លទ្ធភាពឲ្យខ្ញុំបានបន្តការសិក្សាថ្នាក់វិទ្យាល័យ

+លោកគ្រូ លឹម ផល្គុន និង លោកគ្រូ ឡូវ ហុង និង លោកគ្រូ យិន និល ដែលបាន បង្ហាត់បង្រៀនខ្ញុំបាទឲ្យមានសមត្ថភាពអាចរៀបរៀងសៀវភៅនេះបាន

+លោក ចេង អឿន (ប្រធានគ្រប់គ្រងមណ្ឌល AFS)និង លោក ទឹម កាន (អនុប្រធានគ្រប់គ្រងមណ្ឌល AFS) ដែលលើកទឹកចិត្តនិង គាំទ្រការសិក្សារបស់ខ្ញុំ

+មិត្ត អ៊ាង ចិត្រា ដែលជួយត្រួតពិនិត្យអក្ខរាវិរុទ្ធ

មហិទ្ធិគណិតវិទ្យា Maths Ambition

អារម្ភកថា

សួស្តីមិត្តអ្នកស្រលាញ់វិស័យគណិតវិទ្យា!

សៀវភៅ"**៨២លំហាត់និងដំណោះស្រាយ**"នេះស្នាដៃរ ដំបូងរបស់ខ្ញុំសំរាប់បំរើដល់មហាជនក្នុងវិស័យគណិត វិទ្យា។ ខ្ញុំបាទមានចិត្តរីករាយជាខ្លាំងដែលបានរៀបរៀង សៀវភៅនេះឡើង។ទោះជាយ៉ាងណាក៏ដោយខ្ញុំគិតថា កំហុសលើផ្នែកអក្ខរាវិរុទ្ធ ផ្នែកបំណកស្រាយអាចកើត មានដោយអចេតនា។ ក្នុងនាមខ្ញុំជាអ្នកជាអ្នករៀបរៀង មានចិត្តរីករាយសោមនស្សចំពោះការិះគន់បែបស្ថាបនាពី សំណាក់មិត្តអ្នកអានដើម្បីកែលំអសៀវភៅនេះអោយ កាន់តែប្រសើរឡើងជាងមុន។

ជាចុងក្រោយនេះខ្ញុំសូមជូនពរដល់មិត្តអ្នកអានអោយមាន សុខភាពល្អប្រាជ្ញាឆ្លាតវ័យនិង សំរេចរាល់បំណង ប្រកប ដោយគតិបណ្ឌិតគ្រប់ប្រការ។

បាត់ដំបងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១

ឃន វ៉ាន់នី

Email : khonvanny@gmail.com

លំហាត់

1. គេអោយ a,b,c ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។បង្ហាញថា

$$\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}+\frac{(c+a-b)^4}{a(a+b-c)} \geq ab+bc+ca$$

(Greece National Olympaid 2007)

2.គេអោយត្រីកោណABCកែងត្រង់C។បង្ហាញថាអង្កត់ផ្ចិតរង្វង់ចារឹកក្នុង

ត្រីកោណនេះស្មើa+b-cដែលAC=b,BC=a,AB=c។

(Indonesia National Science Olympaid 2004)

3. រង្វង់ពីរប្រសព្វគ្នាត្រង់A,B បន្ទាត់គូសតាមAកាត់រង្វង់ទាំងពីរ ត្រង់ P,Q ។

ស្រាយថាBP/BQមិនអាស្រ័យនិង ការប្រែប្រួលនៃបន្ទាត់(PQ)។(កម្ពុជា2007)

4. អោយបួនចំនុច A,B,C,D រត់ត្រង់គ្នាតាមលំដាប់នេះ។គេគូសរង្វង់(Γ)

កាត់តាម ចំនុច A,B។ គូសរង្វង់កាត់តាមចំនុច B,C ប៉ះរង្វង់ (Γ)។

(Cambodia IMO team Select Test 2011)

5. AD ជាកំពស់គូសពីកំពូល A នៃត្រីកោណកែងABC។ស្រាយបញ្ជាក់ថា

AD ស្មើផលបូកនៃកាំរង្វង់ចារឹកក្នុងត្រីកោណ $\Delta ABC, \Delta ABD, \Delta ACD$ ។

(Olympic Turkey 1997)

6. AD ជាកំពស់គូសពីកំពូល A នៃត្រីកោណកែងABC ។បន្ទាត់គូស

កាត់តាមផ្ចិតរង្វង់ចារឹកក្នុងត្រីកោណABD,ACDប្រសព្វអង្កត់AB,ACត្រង់ K,L

រៀងគ្នា។ តាង E, E ជាក្រលាផ្ទៃនៃត្រីកោណ ABC,AKLរៀងគ្នា។

ស្រាយបញ្ជាក់ថា $\frac{E}{E_1} \ge 2$ (IMO Shortlist 1988)

7. អោយត្រីកោណ ABC មួយ ។ គេដៅចំនុចN,Mលើជ្រុងAB,AC ដែល NB=BC=CM។គណនាផលធៀប $\frac{MN}{BC}$ជាអនុគមន៍នៃ R,r ដែលR,r ជាកាំរង្វង់ចារឹកក្រៅនិងចារឹកក្នុងត្រីកោណABC ។(APMO 2005)

A

8. តាងw,x,y,zជាចំនួនមិនអវិជ្ជមានដែលwx+xy+yz+zw=1 ។ស្រាយថា

$$\frac{w^3}{x+y+z}+\frac{x^3}{w+y+z}+\frac{y^3}{w+x+z}+\frac{z^3}{w+x+y} \ge \frac{1}{3}$$

(IMO Shortlist 1990)

9. អង្កត់ធ្នូAB,CD ប្រសព្វគ្នាត្រង់E។Mជាចំនុចលើអង្កត់BE ។បន្ទាត់ប៉ះត្រង់Eលើរង្វង់កាត់តាមចំនុចD,E,Mប្រសព្វបន្ទាត់BC.ACរៀងគ្នាត្រង់F,Gរៀងគ្នា។បើ $t=\frac{AM}{AB}$ គណនា $\frac{EG}{EF}$ ជាអនុគមន៍នៃt។(IMO 1990)

10.កំណត់4ចំនួនពិតx_1, x_2, x_3, x_4 ដែលផលបូកចំនួនមួយនិង ផលគុណបីចំនួនផ្សេងទៀតស្មើ2។ (IMO 1965)

11. គេអោយបីចំនួនពិតវិជ្ជមានa,b,c ដែលផលបូកស្មើ6។រកតម្លៃធំបំផុតនៃ $\sqrt[3]{a^2+2bc}+\sqrt[3]{b^2+2ca}+\sqrt[3]{c^2+2ab}$ ។

(Greece Nation Mathematic Olympaid 2011)

12. យកMជាចំនុចកណ្ដាលBCនៃត្រីកោណABC។Hជាអ័រតូសង់នៃត្រីកោណABC។បន្ទាត់គូសកាត់តាមHកែងនឹងAMត្រង់P។ ស្រាយបញ្ជាក់ថា

$BM^2 = AM.PM$ (Japan Mathematical Olympaid finals 2011)

13. អោយa,b,c,dជាចំនួនពិតវិជ្ជមាន ។ស្រាយបញ្ជាក់ថា

$$\frac{a}{b+2c+3d}+\frac{b}{c+2d+3a}+\frac{c}{d+2a+3b}+\frac{d}{a+2b+3c}\geq\frac{2}{3}$$

(IMO Shortlist 1993)

14. តាងO ជាចំនុចប្រសព្វរវាងអង្កត់ទ្រូងAC,BDនៃចតុកោណប៉ោងABCD។ រង្វង់ចារឹកក្រៅត្រីកោណ OAD, OBC ប្រសព្វគ្នាត្រង់ M ។បន្ទាត់កាត់តាមចំនុច O,M កាត់រង្វង់ចារឹកក្រៅត្រីកោណAOB, COD រៀងគ្នាត្រង់ S,T ។ ស្រាយបញ្ជាក់ថា M ជាចំនុចកណ្តាលអង្កត់ ST ។

(China Girls' Mathematical Olympaid 2006)

15. កំណត់គូចំនួនពិត(x,y)ដែលផ្ទៀងផ្ទាត់

$$\begin{cases} x^3-y^3=4(x-y) & (1) \\ x^3+y^3=2(x+y) & (2) \end{cases}$$

(Indonesia National Science Olympaid 2006)

16. រកចំនួនគត់ $n\in\{1,2,3........,2009\}$ ដែលផ្ទៀងផ្ទាត់ $4n^6+n^3+5$ ចែកដាច់នឹង7។ (Indonesia National Science Olympaid 2009)

17. កំណត់គ្រប់គូចំនួនគត់(x,y)ដែល

$$x^2-y^4=2009$$

(Spain Mathematical Olympaid 2009)

18. គេអោយa,b,cជាចំនួនគត់វិជ្ជមាន ។បើ $30|a+b+c$

ស្រាយបញ្ជាក់ថា $30|a^5+b^5+c^5$

(Indonesia National Science Olympaid 2006)

19. កំណត់គូចំនួនគត់វិជ្ជមាន(x,y)ដែលផ្ទៀងផ្ទាត់ $\frac{x+y}{x^2-xy+y^2}=\frac{3}{7}$ ។

(Taiwan National Olympaid 2005)

20. កំណត់ចំនួនពិត(x,y,z)ដែលផ្ទៀងផ្ទាត់ប្រព័ន្ធសមីការ

$$\begin{cases} x = y^3 + y - 8 \\ y = z^3 + z - 8 \\ z = x^3 + x - 8 \end{cases}$$

(Indonesia National Science Olympaid 2007)

21.គេអោយចំនួនកុំផ្លិច z_1 , z_2 ដែល $z_1 = -1+i, z_2 = 2+4i$

រកចំនួនកុំផ្លិច z_3 ដែលអានិចនៃ z_1 , z_2 , z_3 ជាកំពូលទាំង3នៃត្រីកោណសម័ង្ស ។(Kosovo National Mathematical Olympaid 2011)

22. បង្ហាញថា $\sum_{n=1}^{9999} \frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)} = 9$

(Proposted by Dr Dorin Andrica)

23. តាងa,b,cជាចំនួនពិតវិជ្ជមានដែលab+bc+ca=1 ។ ស្រាយបញ្ជាក់ថា

$$\left(a+\frac{1}{b}\right)^2 + \left(b+\frac{1}{c}\right)^2 + \left(c+\frac{1}{a}\right)^2 \geq 16$$

(Proposted By Mircea Becheanu,Bucharest,Romanai)

24.មេដ្យានAMនិងកន្លះបន្ទាត់ពុះមុំBNប្រសព្វគ្នាត្រង់P ។បន្ទាត់CPប្រសព្វបន្ទាត់ABត្រង់Q ។ស្រាយបញ្ជាក់ថាត្រីកោណBNQជាត្រីកោណសមបាត ។

(Proposted by Dr Dorin Andrica)

25. កំណត់ចំនួនគត់វិជ្ជមាន(x,y,z)ដែល

$$x^2+2xy+y^2-z^2=9$$

(Malaysia National Olympaid 2010)

26. តាង a,b,c ជាចំនួនពិតវិជ្ជមានដែល abc=1។ស្រាយថា

$$\frac{a}{(a+1)(b+1)}+\frac{b}{(b+1)(c+1)}+\frac{c}{(c+1)(a+1)}\geq\frac{3}{4}$$

(France Team Selection Test 2006)

27.តាងa,b,cជាជ្រុងនៃត្រីកោណមួយដែល a+b+c=3។ កំណត់តំលៃតូចបំផុតនៃ

$$a^2+b^2+c^2+\frac{4abc}{3}$$

(China Norther olympaid 2007)

28. គេអោយ x,y,z ជាចំនួនពិតវិជ្ជមាន។ បង្ហាញថា

$$\frac{1+zx+zy}{(1+x+y)^2}+\frac{1+xy+xz}{(1+y+z)^2}+\frac{1+yz+yx}{(1+z+x)^2}\geq 1$$

(Japan Mathematical Olympaid finals 2010)

29. តាង a,b,c ជាចំនួនពិតវិជ្ជមាន។ ស្រាយបញ្ជាក់ថា

$$\frac{a+b+3c}{3a+3b+2b}+\frac{b+c+3a}{3b+3c+2a}+\frac{c+a+3b}{3c+3a+2b}\geq\frac{15}{8}$$

(Spain Mathematical Olympaid 2010)

30. គេអោយABC ជាត្រីកោណមាន Γ ជារង្វង់ចារឹកក្រៅ។M ជាចំនុចនៅក្នុងត្រីកោណABC និងលើបន្ទាត់ពុះមុំA ផងដែរ។ បន្ទាត់AM,BM,CM ជួបរង្វង់ត្រង់ A_1,B_1,C_1 រៀងគ្នា។ ឧបមាថាP ជាចំនុចប្រសព្វនៃ A_1C_1 និងAB។ Qជាចំនុចប្រសព្វនៃ A_1B_1 និងAC។ ស្រាយថាបន្ទាត់PQ ស្របបន្ទាត់BC។

(India National Olympaid 2010)

31. ចំពោះគ្រប់ចំនួនពិតវិជ្ជមានa,b,c,d ចូរបង្ហាញថា

$$\sqrt{a^4+c^4}+\sqrt{a^4+d^4}+\sqrt{b^4+c^2}+\sqrt{b^4+d^4}\geq 2\sqrt{2}(ad+bc)$$

(Turkey National Olympiad 2005)

32. អោយa,b,c ជាចំនួនពិតវិជ្ជមាន និង a+b+c=1 ។ បង្ហាញថា

$$\sqrt{\frac{ab}{ab+c}}+\sqrt{\frac{bc}{bc+a}}+\sqrt{\frac{ca}{ca+b}}\leq\frac{3}{2}$$

(Kyrgyzstan National Olympaid 2010)

33. បីចំនុចខុសគ្នា A, B, C ស្ថិតក្នុងរង្វង់ (O) មួយ។ បន្ទាត់ប៉ះ (O)

ត្រង់ A និង B ប្រសព្វគ្នាត្រង់ P។បន្ទាត់ប៉ះ (o) ត្រង់Cកាត់បន្ទាត់ AB ត្រង់Q។

បង្ហាញថា $PQ^2=PB^2+QC^2$

(Mathematical Olympaid In Poland 2002)

34.គេអោយត្រីកោណកែងពីរ ដែលរង្វង់ចារឹកក្នុងត្រីកោណាមួយស្មើរង្វង់ចារឹកក្រៅ

ត្រីកោណាមួយទៀត។តាងS,S_1 ជាក្រលាផ្ទៃត្រីកោណា ទាំងពីរខាងលើរៀងគ្នា។

បង្ហាញថា $\dfrac{S}{S_1}\geq 3+2\sqrt{2}$

(France Team Selection Test 2005)

35. គេអោយx,y,z ជាចំនួនពិតដែល $0\leq x.y.z\leq 1$។

បង្ហាញថា $xyz+(1-x)(1-y)(1-z)\leq 1$

(Slovania National Olympaid 2010)

36.ឧបមាថា a,b,c ជាចំនួនពិតវិជ្ជមានដែល (a+b)(b+c)(c+a)=1

ស្រាយបញ្ជាក់ថា $ab+bc+ca \le \frac{3}{4}$

(Croatia Team Selection Tests 2006)

37. អង្កត់ទ្រូងនៃចតុកោណព្នាយ ABCD ចែកចតុកោណព្នាយជាត្រីកោណ4។ s_1និងs_2ជាផ្ទៃក្រឡានៃត្រីកោណដែលមានជ្រុងមួយជាបាទចតុកោណព្នាយ។ រកផ្ទៃក្រឡាSនៃចតុកោណព្នាយអនុគមន៍នឹង s_1និងs_2។

(ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសកម្ពុជាថ្នាក់ទី៩ ឆ្នាំ ២០១១)

38. គេអោយត្រីកោណសមបាតABC កំពូលA ផ្ទៃក្រលា S។MNជាបាតមធ្យម ត្រូវនឹងបាត BC ហើយ O ជាប្រសព្វនៃ MN និងកំពស់គូសចេញពីកំពូល A ។ គេបន្លាយ[CO) កាត់AB ត្រង់D និងបន្លាយ[BO) កាត់AC ត្រង់E ។ ចូររកក្រលាផ្ទៃនៃចតុកោណ ADOE អនុគមន៍ទៅនឹង S។

(ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសកម្ពុជាថ្នាក់ទី៩ ឆ្នាំ ២០១១)

39. តាងa,b,cជាចំនួនពិតវិជ្ជមាន។បង្ហាញថា

$$\frac{a^2}{a^2+2bc}+\frac{b^2}{b^2+2ca}+\frac{c^2}{c^2+2ab}\ge 1\ge \frac{bc}{a^2+2bc}+\frac{ca}{b^2+2ca}+\frac{ab}{c^2+2ab}$$

(Romania 1997)

40. តាង a, b, c ជាចំនួនពិតវិជ្ជមានដែល abc=1។ស្រាយថា

$$\frac{1+ab^2}{c^3}+\frac{1+bc^2}{a^3}+\frac{1+ca^2}{b^3}\ge \frac{18}{a^3+b^3+c^3}$$

(Hong Kong 2000)

41-គេអោយត្រីកោណ ABC មួយមានជ្រុង AB, BC, CA បង្កើតបាន

ជាស្វ៊ីតនព្វន្តមួយ ។

ក-បង្ហាញថា SinA,SinB,SinC បង្កើតបានជាស្វ៊ីតនព្វន្តមួយ។

ខ- បង្ហាញថាផលគុណ $\tan\frac{B}{2}\tan\frac{C}{2}$មានតំលៃថេរ។

(ប្រឡងជ្រើសរើសបេក្ខជនចូលរួមប្រឡង APMO របស់កម្ពុជាឆ្នាំ 2009)

42-ត្រីកោណសមបាត ABC មួយមានមុំ $\angle A=90$ ។យក M ជាចំនុចកណ្តាល

នៃAB។បន្ទាត់មួយគូសចេញពីAហើយកែងនឹងCMកាត់ជ្រុងBCត្រង់P។

បង្ហាញថា $\angle AMC=\angle BMP$ ។

(Baltic Way 2000)

43 កំណត់គ្រប់អនុគមន៍ $f:[0,+\infty)\to[0,+\infty)$ដែលផ្ទៀងផ្ទាត់

$$(y+1)f(x+y)=f(xf(y))$$

គ្រប់ចំនួនពិត មិនអវិជ្ជមានx,y

(Slovenia National Olympaid 2010)

44. ចំពោះចំនួនពិត t និងចំនួនពិតវិជ្ជមាន a,b យើងមាន

$$2a^2-3abt+b^2=2a^2+abt-b^2=0$$

ចូរកំណត់ t ។

(Slovenia National Olympaid 2010)

45. កំណត់ចំនួនពិត x នៅចន្លោះ $[0,2\pi)$ ដែល

$$27.3^{3\sin x}=9^{\cos^2 x}$$

(Slovenia National Olympaid 2010)

46.រង្វង់ចារឹកក្រៅ ABC ត្រីកោណប៉ះជ្រុង BC និង AC ត្រង់D និងE រៀងគ្នា។ បង្ហាញថាបើ AD=BE នោះ ABC ជាត្រីកោណសមបាត។

(Austraian Mathematical Olympaid 2006)

47.ចតុកោណប៉ោង ABCD មួយ យកEជាប្រសព្វរវាងអង្កត់ទ្រូងហើយ S_1, S_2 S ជាក្រលាផ្ទៃនៃ ABE, CDE និង ABCD រៀងគ្នា។

ចូរស្រាយថា $\sqrt{S_1}+\sqrt{S_2}\le\sqrt{S}$

(Austraian Mathematical Olympaid 1990)

48. ចំនុច D និង E ស្ថិតនៅលើជ្រុងBCនិងACនៃត្រីកោណABCបន្ទាត់ ADនិងBEប្រសព្វគ្នាត្រង់P។KនិងLជាចំនុចនៅលើជ្រុងBCនិងACរៀងគ្នា ដែលCLPKជាប្រលេឡូក្រាម។ បង្ហាញថា $\frac{AE}{EL}=\frac{BD}{DK}$

(Mathematical Olympaid In Poland 2000)

49. គេឲ្យr,s,tជាឫសនៃពហុធាដឺក្រេទីបី

$$P(x)=x^3-2007x+2002$$

គណនាតំលៃនៃ $\frac{r-1}{r+1}+\frac{s-1}{s+1}+\frac{t-1}{t+1}$

(Irish Mathematical Olympaid 2007)

50. គេឲ្យ ABC ជាត្រីកោណដែល $\angle BAC \neq 90$ ។ យក O ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ ABC និង Γ ជា ផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ OBC ។ ឧបមាថា Γ ប្រសព្វនឹងអង្កត់ AB ត្រង់ P ខុសពី B និង Γ ប្រសព្វនឹងអង្កត់ AC ត្រង់ Q ខុសពី C ។ តាង ON ជាអង្កត់ផ្ចិតនៃរង្វង់ Γ ។ បង្ហាញថាចតុកោណ APNQ ជាប្រលេឡូក្រាម។ (APMO 2010)

51. ក- កំណត់គ្រប់ចំនួនគត់ធម្មជាតិ n ដោយដឹងថា 2^n-1 ចែកដាច់នឹង 7 ។

ខ-ចូរបង្ហាញថាគ្មានចំនួនគត់ធម្មជាតិ n ណាដែល 2^n+1 ចែកដាច់នឹង 7 ។

(IMO 1964)

52.គេឲ្យ a, b, c ជាចំនួនពិតវិជ្ជមានដែល (a+b)(b+c)(c+a)=8

បង្ហាញថា $\dfrac{a+b+c}{3} \geq \sqrt[27]{\dfrac{a^3+b^3+c^3}{3}}$

(Macedonia National Olympaid 2008)

53.គេឲ្យa,b,cជាចំនួនពិតវិជ្ជមានដែលa+b+c=1 ។បង្ហាញថា

$$a\sqrt[3]{1+b-c}+b\sqrt[3]{1+c-a}+c\sqrt[3]{1+a-b} \leq 1$$

(Bosnia Herzegovina Team Selection Test 2011)

54. គេឲ្យa,b,cជាចំនួនពិតវិជ្ជមានដែល ។បង្ហាញថា

$$\sqrt{a^4+b^4+c^4}+\sqrt{a^2b^2+b^2c^2+c^2a^2} \geq \sqrt{a^3b+b^3c+c^3b}+\sqrt{ab^3+bc^3+ca^3}$$

(KMO Summer Program Test 2001)

55. កំណត់តំលៃធំបំផុតនិងតូចបំផុតនៃx+y ដែលx,y ជាចំនួន

ពិតដែលx≥-2,y≥-3 និង $x-2\sqrt{x+2}=y-2\sqrt{y+3}$

(Irish Mathematical Olympaid 2006)

56. បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែងលុះត្រាតែ

$\text{Sin}^2A+\text{Sin}^2B+\text{Sin}^2C=2$

(Irish Mathematical Olympaid 2007)

57.កំណត់គ្រប់អនុគមន៍f ដែលកំណត់ពីសំណុំចំនួនពិត$\Re$ចូលក្នុងសំណុំចំនួនពិត

ដែលផ្ទៀងផ្ទាត់គ្រប់ x, y, z$\in\Re$ មានសមភាព

$$f(f(x)+f(y)+f(z))=f(f(x)-f(y))+f(2xy+f(z))+2f(xz-yz)$$

(APMO 2010)

58.ឲ្យត្រីកោណ ABC មួយតាងរង្វាស់ជ្រុង BC, AC, AB រៀងគ្នាដោយ

a, b, c កន្លះពុះមុំក្នុងនៃមុំ$\angle$BAC, $\angle$ABC, $\angle$ACB ជួបជ្រុងBC, AC, AB

រៀងគ្នាត្រង់D, E, F តាង AD, BE, CF ដោយd, e, f រៀងគ្នា។

បង្ហាញថា

$$def=\frac{4abc(a+b+c)\Delta}{(a+b)(b+c)(c+a)}$$

ដែលΔជាក្រលាផ្ទៃនៃត្រីកោណABC។

(Irish Mathematical Olympaid 2007)

59-ចំនួនគត់វិជ្ជមានហៅថា *" good number "* បើវាស្មើបួនដងនៃ

ផលបូកលេខលំដាប់ក្នុងប្រពន្ធ័ដេស៊ីម៉ាលរបស់វា។

កំណត់ផលបូកគ្រប់ចំនួន*" good number "* ។

(China Northern mathematical Olympaid 2002)

60.គេឲ្យ a,b,c ជាចំនួនពិតវិជ្ជមាន។បង្ហាញថា

$$\sqrt{a^2-ab+b^2}+\sqrt{b^2-bc+c^2}\ge\sqrt{a^2+ac+c^2}$$

(Baltic Way 2000)

61.កំណត់គ្រប់គូចំនួនគត់ (x,y) ដែល $x^2-2xy+126y^2=2009$ ។

(China South East Mathematical Olympaid 2009)

62.តាង x, y, z ជាចំនួនពិតវិជ្ជមាន។កំណត់តំលៃតូចបំផុតនៃ

a) $\dfrac{x^2+y^2+z^2}{xy+zy}$ b) $\dfrac{x^2+y^2+2z^2}{xy+zy}$

(Croatia Team Selection Tests 2008)

63.គេឲ្យ a, b, c, d ជាចំនួនពិតវិជ្ជមាន។ បង្ហាញថា

$$\frac{a-b}{b+c}+\frac{b-c}{c+d}+\frac{c-d}{d+a}+\frac{d-a}{a+b}\ge 0$$

(Croatia Team Selection Tests 2009)

64-កំណត់អនុគមន៍ទាំអស់ពីសំនុំចំនួនគត់វិជ្ជមានទៅសំនុំចំនួនគត់វិជ្ជមាន ដែល

ផ្ទៀងផ្ទាត់: ចំពោះគ្រប់ចំនួនគត់វិជ្ជមានa និងb មានត្រីកោណាមួយដែលមានជ្រុង

របស់វាមានប្រវែង $a, f(b)$ និង $f(a+f(b)-1)$

(IMO 2009)

1. គេអោយ a,b,c ជារង្វាស់ជ្រុងនៃត្រីកោណមួយៗបង្ហាញថា

$$\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}+\frac{(c+a-b)^4}{a(a+b-c)}\geq ab+bc+ca$$

(Greece National Olympaid 2007)

សម្រាយ

តាមវិសមភាព **AM-GM** យើងពិនិត្យឃើញថា

$$\frac{(a+b-c)^4}{b(b+c-a)}+b(b+c-a)\geq 2(a+b-c)^2$$

វិសមភាពសមមូល

$$\frac{(a+b-c)^4}{b(b+c-a)}\geq 2a^2+2c^2+b^2+5ab-5bc-4ac$$

យើងបាន

$$\frac{(a+b-c)^4}{b(b+c-a)}\geq b^2+5ab-5bc \quad (1)$$

ដូចគ្នាដែរ

$$\frac{(b+c-a)^4}{c(c+a-b)}\geq c^2+5bc-5ac \quad (2)$$

$$\frac{(c+a-b)^4}{a(a+b-c)}\geq a^2+5ac-5ab \quad (3)$$

បូកអង្គនិងអង្គនៃវិសមភាព(1),(2)និង(3)យើងបាន

$$\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}+\frac{(c+a-b)^4}{a(a+b-c)}\geq a^2+b^2+c^2 \quad (4)$$

ម្យ៉ាងទៀតតាមវិសមភាព **C-S** យើងមាន

$$(ab+bc+ca)^2 \le (a^2+b^2+c^2)(a^2+b^2+c^2)$$

យើងបាន

$$(ab+bc+ca)\le (a^2+b^2+c^2) \quad (5)$$

តាម(4)និង(5)

$$\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}+\frac{(c+a-b)^4}{a(a+b-c)}\ge ab+bc+ca$$

វិសមភាពខាងលើត្រូវបានស្រាយបញ្ជាក់ ។

2.គេអោយត្រីកោណABCកែងត្រង់C ។បង្ហាញថាអង្កត់ផ្ចិតរង្វង់ចារឹកក្នុងត្រីកោណនេះស្មើa+b-cដែលAC=b,BC=a,AB=c ។

(Indonesia National Science Olympaid 2004)

សម្រាយ

តាង k,r ជាកន្លះបរិមាត្រ កាំរង្វង់ចារឹកក្នុងនៃត្រីកោណ ABC រៀងគ្នា ។

តាមរូបមន្តក្រលាផ្ទៃយើងបាន

$$S_{ABC}=kr=\frac{bc}{2}=\frac{(b+c)^2-(b^2+c^2)}{4}=\frac{(b+c)^2-a^2}{4}$$

$$=\frac{(a+b+c)(b+c-a)}{4}=\frac{k(b+c-a)}{2}$$

$$\Rightarrow r=\frac{b+c-a}{2}$$

3. រង្វង់ពីរប្រសព្វគ្នាត្រង់A,Bបន្ទាត់គូសតាម Aកាត់រង្វង់ទាំងពីរ ត្រង់ P,Q ។ ស្រាយថាBP/BQមិនអាស្រ័យនឹងការប្រែប្រួលនៃបន្ទាត់(PQ)។(កម្ពុជា2007)

សម្រាយ

យើងមាន

$$\angle APB = \frac{1}{2}\angle AO_1B$$

$$\angle AQB = \frac{1}{2}\angle AO_2B$$

សុទ្ធតែថេរ (O_1,O_2ជាផ្ចិតនៃរង្វង់ទាំពីរ)។តាមទ្រឹស្តីបទស៊ីនុសយើងមាន

$$\frac{PB}{Sin\angle PAB} = \frac{AB}{Sin\angle APB}$$

$$\Rightarrow PB = \frac{ABSin\angle PAB}{Sin\angle APB}$$

$$\frac{QB}{Sin\angle QAB} = \frac{AB}{Sin\angle AQB} = \frac{QB}{Sin(180-\angle PAB)}$$

$$\Rightarrow QB = \frac{ABSin\angle PAB}{Sin\angle AQB}$$

$$\Rightarrow \frac{BP}{BQ} = \frac{Sin\angle AQB}{Sin\angle APB}$$ ថេរ

4. អោយបួនចំនុច A,B,C,D រត់ត្រង់គ្នាតាមលំដាប់នេះ។គេគូសរង្វង់(Γ) កាត់តាម ចំនុច A,B។ គូសរង្វង់កាត់តាមចំនុច B,C ប៉ះរង្វង់ (Γ)។

(Cambodia IMO team Select Test 2011)

សម្រាយ

តាង (ϖ) ជារង្វង់ដែលត្រូវគូស ។ យក E, K ជាចំនុចប៉ះនៃរង្វង់ទាំងពីរនិងជាចំនុចប្រសព្វរវាងបន្ទាត់ប៉ះត្រង់ E ជាមួយបន្ទាត់ (AD) រៀងគ្នា ។ យក I ជាជាផ្ចិតរង្វង់(ϖ) ។ដើម្បីគូសរង្វង់នេះគ្រាន់តែរកទីតាំង I ។

+បើ AB ជាអង្កត់ផ្ចិតរង្វង់ (Γ) នោះI ត្រូវជាចំនុចកណ្តាល CB ។ ដែលB,C ត្រួតលើគ្នា ។



-ករណីABមិនមែនជាអង្កត់ផ្ចិត

តាមទ្រឹស្តីបទស្វ័យគុណចំនុច K ធៀបនឹងរង្វង់ (ϖ) និង (Γ) យើងបាន



$$EK^2 = KC.KD = KB.KA$$

$$\Leftrightarrow \frac{KC}{KB} = \frac{KA}{KD} = \frac{AC}{BD} = \frac{BC - KB}{KB}$$

$$\Leftrightarrow KB = \frac{BC.BD}{BD + AC}$$

នោះkជាចំនុចប្រសព្វនៃអង្កត់ [BC] ជាមួយរង្វង់ផ្ចិតBកាំ $r = \frac{BC.BD}{BD + AC}$

បន្ទាប់មកតាម k គូសបន្ទាត់ប៉ះលើរង្វង់(Γ)យើងបានសង់ចំនុច E ។

ចំនុចប្រសព្វនៃមេដ្យាទ័អង្កត់[CE] និង [ED] ជាចំនុច Iគូសរង្វង់ផ្ចិតI កាំ ID ។

រង្វង់(ϖ) ត្រូវបានសង់ ។

5. AD ជាកំពស់គូសពីកំពូល A នៃត្រីកោណកែងABC។ស្រាយបញ្ជាក់ថា AD ស្មើផលបូកនៃកាំរង្វង់ចារឹកក្នុងត្រីកោណ $\Delta ABC, \Delta ABD, \Delta ACD$ ។

(Olympic Turkey 1997)

សម្រាយ

តាង r, r_1និង r_2ជាកាំរង្វង់ចារឹកក្នុងត្រីកោណABC, ABD និង ACDរៀងគ្នា

តាមលំហាត់ទី2យើងបាន

$$r = \frac{AC + AB - AC}{2}, r_1 = \frac{AD + DB - AB}{2}, r_2 = \frac{AD + CD - AC}{2}$$

បូកអង្គនិងអង្គនៃសមភាពខាងលើយើងបាន

$$r + r_1 + r_2 = \frac{AC + AB - AC}{2} + \frac{AD + DB - AB}{2} + \frac{AD + CD - AC}{2}$$

$$= AD$$

ព្រោះ CD+DB=BC

ដូចនេះ AD ស្មើផលបូកនៃកាំរង្វង់ចារឹកក្នុងត្រីកោណABC, ABD,ACD។

6. AD ជាកំពស់គូសពីកំពូល A នៃត្រីកោណកែងABC ។បន្ទាត់គូស កាត់តាមផ្ចិតរង្វង់ចារឹកក្នុងត្រីកោណABD,ACDប្រសព្វអង្កត់AB,ACត្រង់ K,L រៀងគ្នា។ តាង E, E_1ជាក្រលាផ្ទៃនៃត្រីកោណ ABC,AKLរៀងគ្នា។ ស្រាយបញ្ជាក់ថា $\frac{E}{E_1} \geq 2$ (IMO Shortlist 1988)

សម្រាយ

យក r_1,r_2 ជាកាំរង្វង់ចារឹកក្នុងត្រីកោណ ADC.ADC រៀងគ្នា។យក O_1,O_2 ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ ADB , ADC រៀងគ្នា។

យកM, N (M∈AD) ជាចំនុចប៉ះនៃរង្វង់ចារឹកក្នុងត្រីកោណADB យើងបាន

$$\left.\begin{array}{l}\angle O_1MD=\angle O_1ND=\angle MDN=90^\circ\\ O_1M=O_1N=MD=ND\end{array}\right|\Rightarrow$$ ចតុកោណ O_1MDN ជាការេ

$$\Rightarrow \angle O_1DA=45^\circ$$

ដូចគ្នាដែរ

$$\angle O_2DA=45^\circ \Rightarrow \angle O_1DO_2=90^\circ=\angle BAC \quad (1)$$

ម្យ៉ាងទៀតDO$_1$ជាអង្កត់ទ្រូងការេ O_1KDL មានជ្រុងO$_1$Kជាកាំរង្វង់ចារឹកក្រៅត្រីកោណ ADB យោងតាមសំរាយលំហាត់ទី 2 យើងទាញបាន

$$O_1D=\frac{\sqrt{2}}{2}\left(AD+DB-AB\right)$$

$$\Rightarrow \frac{O_1D}{AB}=\frac{\sqrt{2}\left(AD+DB\right)}{2AB}-\frac{\sqrt{2}}{2}=\frac{\sqrt{2}\left(\sqrt{DB.DC}+DB\right)}{2\sqrt{BC.DB}}-\frac{\sqrt{2}}{2}$$

$$\frac{O_1D}{AB}=\frac{\sqrt{2}\left(\sqrt{DB}+\sqrt{DC}\right)}{2\sqrt{BC}}-\frac{\sqrt{2}}{2} \quad (2)$$

ស្រាយតាមលំនាំដូចគ្នាដែរ

$$\frac{O_2D}{AC}=\frac{\sqrt{2}\left(\sqrt{DB}+\sqrt{DC}\right)}{2\sqrt{BC}}-\frac{\sqrt{2}}{2} \quad (3)$$

តាម(2)និង(3)យើងបាន

$$\frac{DO_1}{AB}=\frac{DO_2}{AC} \quad (4)$$

តាម(1)និង(4)យើងបាន

$$\Delta ABC \approx DO_1O_2$$

យកTជាចំនុចប្រសព្វនៃបន្ទាត់ស្របBCកាត់តាមA ។Mជាប្រសព្វACនិង

DO_2 ។យើងបាន

$$\left.\begin{array}{l}\angle O_1O_2D = \angle MO_2L = \angle C \\ \angle AMT = \angle DMC\end{array}\right| \Rightarrow \angle ATM = \angle MLK = \angle TDC = 45^\circ$$

$$\Rightarrow AK = AL$$

ម្យ៉ាងទៀត

$$\left.\begin{array}{l}\angle ADM = \angle ALK \\ \angle DAO_2 = \angle O_2AL\end{array}\right| \Rightarrow AD = AL = AK$$

យើងបាន

$$\left.\begin{array}{l}E = AD.BC \\ E_1 = AD.AD\end{array}\right| \Rightarrow \frac{E}{E_1} = \frac{BC}{AD}$$

$$\frac{E}{E_1} = \frac{BC^2}{AD.BC} = \frac{AB^2 + AC^2}{AB.AC}$$

$$\frac{E}{E_1} \geq \frac{2AB.AC}{AB.AC} = 2$$



7. អោយត្រីកោណ ABC មួយ ។គេដៅចំនុចN,Mលើជ្រុងAB,AC ដែល NB=BC=CM ។គណនាផលធៀប $\frac{MN}{BC}$ជាអនុគមន៍នៃ R,r ដែលR,r ជាកាំរង្វង់ចារឹកក្រៅនិងចារឹកក្នុងត្រីកោណABC ។(APMO 2005)

សម្រាយ

ដើម្បីអោយមានចំនុចN, Mលើជ្រុងAB, AC ដែល NB=BC=CM លុះត្រាតែ AB>BC & AC>BC យើងបាន

AM= AC-BC , AN= AB-BCតាងpជាកន្លះបរិមាត្រនិង a=BC, b=AC, c=AB

យើងមាន

$$S_{ABC} = pr = \frac{abc}{4R} = \sqrt{p(p-a)(p-b)(p-c)}$$

$$\Rightarrow (p-a)(p-b)(p-c) = pr^2, abc = 4prR \quad (1)$$

តាមទ្រឹស្តីបទ កូស៊ីនុសក្នុងត្រីកោណABC យើងមាន

$$\cos A = \frac{b^2+c^2-a^2}{2bc} \Leftrightarrow 1-\cos A = 1-\frac{b^2+c^2-a^2}{2bc}$$

$$1-\cos A = \frac{a^2-(b-c)^2}{2} = \frac{(a-b+c)(a+b-c)}{2} = 2(p-b)(p-c)$$

ម្យ៉ាងទៀតតាមទ្រឹស្តីបទ កូស៊ីនុសក្នុងត្រីកោណANM យើងមាន

$$MN^2 = (b-a)^2 + (c-a)^2 - 2(b-a)(c-a)Cos\angle A$$

$$= b^2 - 2ab + a^2 + c^2 - 2ac + a^2 - 2\left(a^2 - a(b+c) + bc\right)Cos\angle A$$

$$MN^2 = b^2 + c^2 - 2bcCos\angle A - 2a(b+c) + 2a(b+c)Cos\angle A$$

$$+2a^2 - 2a^2Cos\angle 2$$

$$MN^2 = a^2 - 2a(b+c)(1 - Cos\angle A) + 2a^2(1 - Cos\angle A)$$

$$= a^2 - 2a(1 - Cos\angle A)(b + c - a)$$

តែ $1 - \cos A = 2(p-b)(p-c)$ យើងបាន

$$MN^2 = a^2 - 2a^2\frac{(p-a)(p-b)(p-c)}{abc} \quad (2)$$

តាម(1)និង(2) យើងបាន

$$MN^2 = a^2 - 2a^2\frac{r^2p}{4Rrp} = a^2 - 2a^2\frac{r}{2R}$$

$$\Rightarrow \frac{MN^2}{BC^2} = 1 - \frac{r}{2R}$$

$$\Rightarrow \frac{MN}{BC} = \sqrt{1 - \frac{r}{2R}}$$

ដូចនេះ $\frac{MN}{BC} = \sqrt{1 - \frac{r}{2R}}$

8. តាង w,x,y,z ជាចំនួនមិនអវិជ្ជមានដែល wx+xy+yz+zw=1 ។ស្រាយថា

$$\frac{w^3}{x+y+z}+\frac{x^3}{w+y+z}+\frac{y^3}{w+x+z}+\frac{z^3}{w+x+y}\ge\frac{1}{3}$$

(IMO Shortlist 1990)

សម្រាយ

យើងមាន

$$1=wx+xy+yz+zw=(z+x)(w+y)\le\frac{(x+y+z+w)^2}{2^2}$$

$$\Rightarrow 4\le(w+x+y+z)^2\le 4\left(w^2+x^2+y^2+z^2\right)$$

យើងមាន

$$\sum_{cyc}\frac{w^3}{x+y+z}=\sum_{cyc}\frac{w^4}{wx+wy+wz}\ge\frac{\left(\sum_{cyc}w^2\right)^2}{2(wx+xy+yz+zw+wy+xz)}$$

តែ

$$(x-y)^2+(y-z)^2+(z-w)^2+(w-z)^2+(z-x)^2+(w-y)^2\ge 0$$

$$\Rightarrow 3\sum_{cyc}w^2\ge 2\sum_{cyc}wx$$

យើងបាន

$$\sum_{cyc}\frac{w^3}{x+y+z}\ge\frac{\sum_{cyc}w^2}{3}\ge\frac{1}{3}$$

ដូចនេះវិសមភាពខាងលើពិត

9. អង្កត់ធ្នូAB,CD ប្រសព្វគ្នាត្រង់E។Mជាចំនុចលើអង្កត់BE ។បន្ទាត់ប៉ះត្រង់Eលើរង្វង់កាត់តាមចំនុចD,E,Mប្រសព្វបន្ទាត់BC.ACរៀងគ្នាត្រង់F,Gរៀងគ្នា។បើ $t=\dfrac{AM}{AB}$ គណនា $\dfrac{EG}{EF}$ ជាអនុគមន៍នៃt។(IMO 1990)

សម្រាយ



យើងមាន

$$\angle CEG=\angle FED=180-\angle GED$$

$$=180-\angle DME=\angle DMB$$

$$\angle ABD=\angle ACD=\angle ACE$$

$$\Rightarrow \Delta MBD\approx\Delta ECG$$

$$\Rightarrow \frac{MB}{EC}=\frac{DM}{EG}\Rightarrow EG=\frac{MD.EC}{MB}\quad(1)$$

ម្យ៉ាងទៀត

$$\angle BAD=\angle MAD=\angle DCB=\angle FCE$$

$$\angle CEF=\angle GED=\angle EMD$$

$$\Rightarrow \Delta CEF\approx\Delta AMD$$

$$\Rightarrow \frac{CE}{EF}=\frac{AM}{MD}\Rightarrow EF=\frac{CE.MD}{AM}\quad(2)$$

ធ្វើផលធៀប(1)និង(2)យើងបាន

$$\frac{EG}{EF}=\frac{\dfrac{MD.EC}{MB}}{\dfrac{EC.MD}{AM}}=\frac{AM}{BM}=\frac{AM}{AB-AM}=\frac{1}{\dfrac{AB-AM}{AM}}=\frac{1}{\dfrac{AB}{AM}-1}=\frac{1}{\dfrac{1}{t}-1}=\frac{t}{1-t}$$

ដូចនេះ $\dfrac{EG}{EF}=\dfrac{t}{1-t}$

10.កំណត់4ចំនួនពិត x_1, x_2, x_3, x_4 ដែលផលបូកចំនួនមួយនិងផលគុណាបីចំនួនផ្សេងទៀតស្មើ2ៗ (IMO 1965)

សម្រាយ

តាមសម្មតិកម្មយើងបាន

$$\begin{cases} x_1 + x_2x_3x_4 = 2(1) \\ x_2 + x_3x_4x_1 = 2(2) \\ x_3 + x_4x_1x_2 = 2(3) \\ x_4 + x_1x_2x_3 = 2(4) \end{cases}$$

ដកអង្គនិងអង្គ(1)និង(2)យើងបាន

$$(x_1 - x_2)(1 - x_3x_4) = 0 \Rightarrow \left[\begin{array}{l} x_1 - x_2 = 0 \\ 1 - x_3x_4 = 0 \end{array}\right. \Rightarrow \left[\begin{array}{l} x_1 = x_2 \\ x_3x_4 = 1 \end{array}\right.$$

បើ $x_1=x_2$ ដកអង្គនិងអង្គ(3)និង(4)យើងបាន

$$(x_3 - x_4)(1 - x_2x_1) = 0 \Rightarrow \left[\begin{array}{l} x_3 - x_4 = 0 \\ 1 - x_2x_1 = 0 \end{array}\right. \Rightarrow \left[\begin{array}{l} x_4 = x_3 \\ x_2x_1 = 1 \end{array}\right.$$

-ករណី $x_3=x_4$ ដកអង្គនិងអង្គ(2)និង(3)យើងបាន

$$(x_2 - x_3)(1 - x_4x_1) = 0 \Rightarrow \left[\begin{array}{l} x_2 - x_3 = 0 \\ 1 - x_4x_1 = 0 \end{array}\right. \Rightarrow \left[\begin{array}{l} x_2 = x_3 \\ x_4x_1 = 1 \end{array}\right.$$

+ចំពោះ

$$x_2 = x_3 \Rightarrow x_1 = x_2 = x_3 = x_4$$

$$(1) \Rightarrow x_1 + x_1^3 = 2 \Leftrightarrow (x_1 - 1)(x_1^2 + x_1 + 2) = 0$$

$$\Rightarrow \left[\begin{array}{l} x_1 = 1 \\ x_1^2 + x_1 + 2 = 0 \quad (\Delta = 1 - 4 \times 2 = -7 < 0) \end{array}\right.$$

នោះសមីការមានចំលើយ $x_1 = x_2 = x_3 = x_4 = 1$

+ចំពោះ$x_1x_4=1$តាម(2)

$x_2+x_3=2=x_1+x_4$

$$\Rightarrow\begin{cases}x_1+x_4=2\\x_1x_4=1\end{cases}\Rightarrow x_1=x_4=1=x_3=x_2$$

នោះសមីការមានចំលើយ$x_1=x_2=x_3=x_4=1$

-ករណី $x_1=x_2=1$

តាម(2)និង(4)យើងបាន

$$\begin{cases}x_3+x_4=2\\x_3x_4=1\end{cases}\Rightarrow x_3=x_4=1=x_1=x_2$$

នោះសមីការមានចំលើយ$x_1=x_2=x_3=x_4=1$

+ចំពោះ$x_1=x_2=-1$ តាម(2)និង(3)

$$\begin{cases}x_3x_4=-3\\x_3+x_4=2\end{cases}\Rightarrow\left[\begin{array}{l}x_3=-1,x_4=3\\x_3=3,x_4=-1\end{array}\right.$$

នោះសមីការមានចំលើយ

$(x_1,x_2,x_3,x_4)\in\{(-1,-1,-1,3),(-1,-1,3.-1)\}$

បើ $x_3x_4=1$ នោះ $x_1+x_2=2$

តាម(3)និង(4)សមីការអាចសរសេរ

$$\begin{cases} x_3^2 + x_1x_2 = 2x_3 \\ x_4^2 + x_1x_2 = 2x_4 \end{cases} \Rightarrow (x_3 - x_4)(x_3 + x_4 - 2) = 0$$

$$\Rightarrow \left[\begin{array}{l} x_3 - x_4 = 0 \\ x_3 + x_4 - 2 = 0 \end{array}\right. \Rightarrow \left[\begin{array}{l} x_3 = x_4 \\ x_3 + x_4 = 2 \end{array}\right.$$

-ករណី $x_3 = x_4 \Rightarrow x_3 = x_4 = \pm 1$

+បើ $x_3 = x_4 = 1$ តាម(1)និង(4)

$$\begin{cases} x_1 + x_2 = 2 \\ x_1x_2 = 1 \end{cases} \Rightarrow x_1 = x_2 = 1$$

នោះសមីការមានចំលើយ$x_1 = x_2 = x_3 = x_4 = 1$

+បើ $x_3 = x_4 = -1$ តាម(1)និង(4)យើងបាន

$$\begin{cases} x_1 + x_2 = 2 \\ x_1x_2 = -3 \end{cases} \Rightarrow \left[\begin{array}{l} x_1 = 1, x_2 = -3 \\ x_1 = -3, x_2 = 1 \end{array}\right.$$

នោះសមីការមានចំលើយ

$$(x_1, x_2, x_3, x_4) \in \{(-1,3,-1,-1), (3,-1,-1.-1)\}$$

ករណី $x_3 + x_4 = 2$ នោះ

$$x_3 = x_4 = 1 \Rightarrow x_1 = x_2 = 1$$

នោះសមីការមានចំលើយ $x_1 = x_2 = x_3 = x_4 = 1$

សរុបមកសមីការមានចំលើយ

$$(x_1, x_2, x_3, x_4) \in \begin{Bmatrix} (1,1,1,1), (-1,-1,-1,3), (-1,-1,3.-1), \\ (-1,3,-1,-1), (3,-1,-1,-1) \end{Bmatrix}$$

11. គេអោយបីចំនួនពិតវិជ្ជមានa,b,c ដែលផលបូកស្មើ6។រកតម្លៃធំបំផុតនៃ $\sqrt[3]{a^2+2bc}+\sqrt[3]{b^2+2ca}+\sqrt[3]{c^2+2ab}$ ។

(Greece Nation Mathematic Olympaid 2011)

សម្រាយ

តាមវិសមភាព Cauchy-Schwart យើងមាន

$$(x+y+z)^2 \le 3(x^2+y^2+z^2)$$

$$(x^2+y^2+z^2)^2 =$$

$$\left(\sqrt{x^3}.\sqrt{x}+\sqrt{y^3}.\sqrt{y}+\sqrt{z^3}.\sqrt{z}\right)^2 \le (x+y+z)(x^3+y^3+z^3)$$

$$\Rightarrow \left(\frac{(x+y+z)^2}{3}\right)^2 \le (x+y+z)(x^3+y^3+z^3)$$

$$\Rightarrow (x+y+z)^3 \le 9(x^3+y^3+z^3)$$

នោះយើងបាន $x+y+z \le \sqrt[3]{9(x^3+y^3+z^3)}$

យក $x=\sqrt[3]{a^2+2bc}, y=\sqrt[3]{b^2+2ca}, z=\sqrt[3]{c^2+2ab}$

យើងបាន

$$\sqrt[3]{a^2+2bc}+\sqrt[3]{b^2+2ca}+\sqrt[3]{c^2+2ab}$$

$$\le \sqrt[3]{9(a+b+c)^2} = \sqrt[3]{9\times 6^2} = 3\sqrt[3]{12}$$

ដូចនេះតំលៃធំបំផុតនៃ $\sqrt[3]{a^2+2bc}+\sqrt[3]{b^2+2ca}+\sqrt[3]{c^2+2ab}$ គឺ $3\sqrt[3]{12}$

12. យកMជាចំនុចកណ្តាលBCនៃត្រីកោណABC។Hជាអ័រតូសង់នៃត្រីកោណABC។បន្ទាត់គូសកាត់តាមHកែងនឹងAMត្រង់P។ ស្រាយបញ្ជាក់ថា

$$BM^2 = AM.PM$$

(Japan Mathematical Olympaid finals 2011)

សម្រាយ

-បើ ABC ជាត្រីកោណកែងត្រង់ A នោះ A, H និង P ត្រួវស៊ីគ្នាយើងបាន

$$AM = PM = \frac{BC}{2} = BM \Rightarrow BM^2 = AM.PM$$

-បើ ABC មានមុំ A ជាមុំស្រួចយក AD, BE ជាកំពស់នៃត្រីកោណនេះក្នុងត្រីកោណ AHP និងត្រីកោណ AMD មាន



$$\left.\begin{array}{l}\angle HAP = \angle DAM \\ \angle APH = \angle ADM = 90^\circ\end{array}\right| \Rightarrow \Delta APH \approx \Delta ADM$$

រឺបាន $\frac{AP}{AD} = \frac{AH}{AM} \Leftrightarrow AP.AM = AD.AH = AM(AM - PM)$

$$\Rightarrow AM.PM = AM^2 - AD.AH \quad (1)$$

ម្យ៉ាងទៀតក្នុងត្រីកោណAHE និងត្រីកោណ ACDមាន

$$\left.\begin{array}{l}\angle HAE = \angle DAC \\ \angle HEA = \angle ADC = 90^\circ\end{array}\right| \Rightarrow \Delta AHE \approx \Delta ACD \Rightarrow \frac{AH}{AC} = \frac{AE}{AD}$$

$$\Leftrightarrow AH.AD = AC.AE$$

តែតាមទ្រឹស្តីបទកូស៊ីនុស

$$AH.AD = AC.AE = AC.ABCos\angle A = \frac{AB^2 + AC^2 - CB^2}{2} \quad (2)$$

ព្រោះ $AE = ABCos\angle A$

ម្យ៉ាងទៀតតាមទ្រឹស្តីបទមេដ្យានយើងមាន

$$AM^2 = \frac{AB^2 + AC^2}{2} - \frac{BC^2}{4} \quad (3)$$

តាម(1),(2)និង(3)យើងទាញបាន

$$AM.PM = \frac{AB^2 + AC^2}{2} - \frac{BC^2}{4} - \left(\frac{AB^2 + AC^2 - BC^2}{2}\right)$$

$$= \frac{BC^2}{4} = BM^2$$

-បើ ABC មានមុំ A ជាមុំទាល យក AD,BE ជាកំពស់នៃត្រីកោណៗ

ក្នុត្រីកោណ APH និងត្រីកោណ ADM យើងមាន

$$\left.\begin{array}{l}\angle HAP = \angle DAM \\ \angle ADM = \angle APH\end{array}\right| \Rightarrow \Delta APH \approx \Delta ADM$$

$$\Rightarrow \frac{AP}{AD} = \frac{AH}{AM} \Leftrightarrow AM.AP = AH.AD$$

$$\Rightarrow AM(AM - PM) = AH.AD$$

$$\Leftrightarrow AM.PM = AM^2 - AH.AD \quad (4)$$

ម្យ៉ាងទៀតក្នុងត្រីកោណ AEH និងត្រីកោណ ADB

$$\left.\begin{array}{l}\angle HAE = \angle BAD \\ \angle AEH = \angle ADB\end{array}\right| \Rightarrow \Delta AEH \approx \Delta ADB$$

$$\Rightarrow \frac{AH}{AB} = \frac{AE}{AD} \Leftrightarrow AH.AD = AB.AE = AB.ACCos(180 - \angle A)$$

នោះ $AH.AD = AB.ACCos\angle A = \dfrac{AB^2 + AC^2 - BC^2}{2} \quad (5)$

ព្រោះ $AE = ABCos\angle A$

ម្យ៉ាងទៀតតាមទ្រឹស្តីបទមេដ្យានយើងមាន

$$AM^2 = \frac{AB^2 + AC^2}{2} - \frac{BC^2}{4} \quad (6)$$

តាម(4),(5)និង(6)យើងបាន

$$AM.PM = \frac{AB^2 + AC^2}{2} - \frac{BC^2}{4} - \left(\frac{AB^2 + AC^2 - BC^2}{2} \right)$$

$$= \frac{BC^2}{4} = BM^2$$

ដូចនេះ $BM^2 = AM.PM$

---

13. អោយ a, b, c, d ជាចំនួនពិតវិជ្ជមានៗស្រាយបញ្ជាក់ថា

$$\frac{a}{b+2c+3d} + \frac{b}{c+2d+3a} + \frac{c}{d+2a+3b} + \frac{d}{a+2b+3c} \geq \frac{2}{3}$$

(IMO Shortlist 1993)

សម្រាយ

យើងមាន

$$\sum_{cyc} \frac{a}{b+2c+3d} = \sum_{cyc} \frac{a^2}{ab+2ac+3ad} \geq \frac{(a+b+c+d)^2}{4(ab+ac+ad+bc+bd+cd)}$$

ពិនិត្យ

$$(a-b)^2 + (a-c)^2 + (a-d)^2 + (b-c)^2 + (b-d)^2 + (c-d)^2 \geq 0$$

$$\Leftrightarrow 3\left(a^2 + b^2 + c^2 + d^2\right) \geq 2 \sum_{a,b,c,d} ab$$

យើងមានសមតាព

$$(a+b+c+d)^2 = \sum_{cyc} a^2 + 2\sum_{cyc} ab \geq \frac{8}{3}\sum_{cyc} ab$$

$$\Leftrightarrow 4\sum_{cyc} ab \leq \frac{3}{2}(a+b+c+d)^2$$

នោះ $$\sum_{cyc} \frac{a}{b+2c+3d} \geq \frac{(a+b+c+d)^2}{\frac{3}{2}(a+b+c+d)^2} = \frac{2}{3}$$

14. តាងOជាចំនុចប្រសព្វរវាងអង្កត់ទ្រូងAC,BDនៃចតុកោណប៉ោង ABCD។ រង្វង់ចារឹកក្រៅត្រីកោណ OAD, OBC ប្រសព្វគ្នាត្រង់ M ។បន្ទាត់កាត់តាម ចំនុច O,M កាត់រង្វង់ចារឹកក្រៅត្រីកោណAOB, COD រៀងគ្នាត្រង់ S,T ។ ស្រាយបញ្ជាក់ថា M ជាចំនុចកណ្តាលអង្កត់ ST ។

(China Girls' Mathematical Olympaid 2006)

សម្រាយ



$\angle DMT + \angle DMO = \angle DMO + \angle DAO = 180$

(ផលបូកមុំក្នុងចតុកោណ ADMO ចារឹកក្នុងរង្វង់)

យើងបាន $\angle DMT = \angle DAO \quad (1)$

ម្យ៉ាងទៀត $\angle DTM = \angle DTO = \angle DCO \quad (2)$

(មុំស្កាត់ធ្នូ DO រួម)

តាម(1)និង(2)យើងបាន $\Delta DMT \approx \Delta DAC$

រំឭក $\dfrac{DM}{MT} = \dfrac{DA}{AC} \Leftrightarrow MT = \dfrac{AC.DM}{AD} \quad (3)$

ម្យ៉ាងទៀត $\angle ADB = \angle ADO = \angle OMA = \angle SMA \quad (4)$ (មុំស្កាត់ធ្នូ រួមAO)

តែ $\angle ASM = \angle ASO = \angle ABO = \angle ABD \quad (5)$

តាម(4)និង(5)យើងបាន $\Delta AMS \approx \Delta ADB$

រំឭក $\dfrac{AM}{MS} = \dfrac{AD}{DB} \Leftrightarrow MS = \dfrac{AM.DB}{AD} \quad (6)$

ធ្វើផលធៀប(3)និង(6)យើងបាន

$$\frac{MT}{MS}=\frac{AC.DM}{AM.BD} \qquad (7)$$

ម្យ៉ាងទៀត

$\angle CAM = \angle OAM = \angle ODM = \angle BOM$ (មុំស្កាត់ធ្នូរួម MO) (8)

តែ

$\angle DBM = \angle ODM = \angle OCM = \angle ACM$ (មុំស្កាត់ធ្នូរួម MO)(9)

តាម(8)និង(9)យើងបាន $\Delta AMC \approx \Delta DMB$

រឿបាក $\frac{AM}{DM}=\frac{AC}{BD}$ (10)

តាម (9) និង (10) យើងបាន

$$\frac{MS}{MT}=\frac{AC.BD}{BD.AC}=1 \Leftrightarrow MS = MT$$

សមភាពនេះបញ្ជាក់ថា M ជាចំនុចកណ្តាលអង្កត់ ST។

15. កំណត់គូចំនួនពិត(x,y)ដែលផ្ទៀងផ្ទាត់

$$\begin{cases} x^3 - y^3 = 4(x-y) & (1) \\ x^3 + y^3 = 2(x+y) & (2) \end{cases}$$

(Indonesia National Science Olympaid 2006)

សំរាយ

-បើ x=y តាម(1)សមីការផ្ទៀងផ្ទាត់តាម(2)យើងបាន

$$2x^3 = 4x \Leftrightarrow x(x^2-2) = 0 \Rightarrow \left[\begin{array}{l} x = 0 \\ x = \pm\sqrt{2} \end{array}\right.$$

នោះសមីការមានរឹស

$$(x,y) \in \{(0,0), (\sqrt{2},\sqrt{2}), (-\sqrt{2},-\sqrt{2})\}$$

-បើx=-yតាម(2) សមីការផ្ទៀងផ្ទាត់តាម(1)យើងបាន

$$2x^3 = 8x \Leftrightarrow x(x^2-4) = 0 \Rightarrow \left[\begin{array}{l} x = 0 \\ x = \pm 2 \end{array}\right.$$

សមីការមានរឹស$(x,y) \in \{(0,0), (2,-2), (-2,2)\}$

-បើ$x \neq y$ & $x \neq -y$ ប្រព័ន្ធសមីការអាចសរសេរ

$$\begin{cases} (x+y)(x^2 - xy + y^2) = 2(x+y) \\ (x-y)(x^2 + xy + y^2) = 4(x-y) \end{cases}$$

$$\Leftrightarrow \begin{cases} x^2 + xy + y^2 = 4 \\ x^2 - xy + y^2 = 2 \end{cases}$$

$$\Leftrightarrow \begin{cases} x^2 + y^2 = 3 \\ xy = 1 \end{cases}$$

$$\Rightarrow (x+y)^2 = 3 + 2 = 5 \Rightarrow x + y = \pm\sqrt{5}$$

+ករណី $x+y=\sqrt{5}$ យើងបាន

$$\begin{cases} xy=1 \\ x+y=\sqrt{5} \end{cases}$$

តាមទ្រឹស្តីបទវ្យែត x, y ជាឫសសមីការ

$$X^2-\sqrt{5}X+1=0$$
$$\Delta=5-4=4$$
$$\Rightarrow X_1=\frac{\sqrt{5}+1}{2}, X_2=\frac{\sqrt{5}-1}{2}$$

សមីការមានឫស

$$(x,y)\in\left\{\left(\frac{\sqrt{5}+1}{2},\frac{\sqrt{5}-1}{2}\right),\left(\frac{\sqrt{5}-1}{2},\frac{\sqrt{5}+1}{2}\right)\right\}$$

បើ $x+y=-\sqrt{5}$ យើងបាន

$$\begin{cases} xy=1 \\ x+y=-\sqrt{5} \end{cases}$$

តាមទ្រឹស្តីបទវ្យែត x, y ជាឫសសមីការ

$$X^2+\sqrt{5}X+1=0$$
$$\Delta=5-4=1$$
$$\Rightarrow X_1=\frac{-\sqrt{5}+1}{2}, X_2=\frac{-\sqrt{5}-1}{2}$$

សមីការមានរឹស

$$(x,y)\in\left\{\left(\frac{-\sqrt{5}+1}{2},\frac{-\sqrt{5}-1}{2}\right),\left(\frac{-\sqrt{5}-1}{2},\frac{-\sqrt{5}+1}{2}\right)\right\}$$

សរុបមកសមីការមានចំលើយ

$$(x,y)\in\left\{\begin{array}{l}(0,0),(2,-2),(-2,2),\left(\sqrt{2},\sqrt{2}\right),\left(-\sqrt{2},-\sqrt{2}\right)\\ \left(\frac{-\sqrt{5}+1}{2},\frac{-\sqrt{5}-1}{2}\right),\left(\frac{-\sqrt{5}-1}{2},\frac{-\sqrt{5}+1}{2}\right)\\ \left(\frac{\sqrt{5}+1}{2},\frac{\sqrt{5}-1}{2}\right),\left(\frac{\sqrt{5}-1}{2},\frac{\sqrt{5}+1}{2}\right)\end{array}\right\}$$

16. រកចំនួនគត់ $n\in\{1,2,3........,2009\}$ ដែលផ្ទៀងផ្ទាត់ $4n^6+n^3+5$ ចែកដាច់នឹង7ៗ (Indonesia National Science Olympaid 2009)

សម្រាយ

-ករណី n ចែកដាច់នឹង7យើងបាន

$n\equiv 0 \pmod 7$

$4n^6\equiv 0 \pmod 7$

$n^3\equiv 0 \pmod 7$

$\Rightarrow 4n^6+n^3+5\equiv 5 \pmod 7$

ដូចនេះ n ចែកដាច់នឹង7មិនយក

-ករណីn ចែក នឹង7អោយសំណល់1 យើងបាន

$$n \equiv 1 \pmod 7$$
$$4n^6 \equiv 4 \pmod 7$$
$$n^3 \equiv 1 \pmod 7$$
$$\Rightarrow 4n^6 + n^3 + 5 \equiv 10 \equiv 3 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់1 មិនយក

- ករណីn ចែក នឹង7អោយសំណល់2 យើងបាន

$$n \equiv 2 \pmod 7$$
$$4n^6 \equiv 4.2^6 \equiv 4 \pmod 7$$
$$n^3 \equiv 2^3 \equiv 1 \pmod 7$$
$$\Rightarrow 4n^6 + n^3 + 5 \equiv 10 \equiv 3 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់ មិនយក

- ករណីn ចែក នឹង7អោយសំណល់3 យើងបាន

$$n \equiv 3 \pmod 7$$
$$4n^6 \equiv 4.3^6 \equiv 4 \pmod 7$$
$$n^3 \equiv 3^3 \equiv -1 \pmod 7$$
$$\Rightarrow 4n^6 + n^3 + 5 \equiv 9 \equiv 2 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់3 មិនយក

- ករណីn ចែក នឹង7អោយសំណល់4 យើងបាន

$$n \equiv 4 \equiv -3 \pmod 7$$

$$4n^6 \equiv 4.(-3)^6 \equiv 4 \pmod 7$$

$$n^3 \equiv (-3)^3 \equiv -1 \pmod 7$$

$$\Rightarrow 4n^6 + n^3 + 5 \equiv 9 \equiv 2 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់4 មិនយក

- ករណីn ចែក នឹង7អោយសំណល់5 យើងបាន

$$n \equiv 5 \equiv -2 \pmod 7$$

$$4n^6 \equiv 4.(-2)^6 \equiv 4 \pmod 7$$

$$n^3 \equiv (-2)^3 \equiv -1 \pmod 7$$

$$\Rightarrow 4n^6 + n^3 + 5 \equiv 9 \equiv 2 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់5 មិនយក

- ករណីn ចែក នឹង7អោយសំណល់6 យើងបាន

$$n \equiv 6 \equiv -1 \pmod 7$$

$$4n^6 \equiv 4.(-1)^6 \equiv 4 \pmod 7$$

$$n^3 \equiv (-1)^3 \equiv -1 \pmod 7$$

$$\Rightarrow 4n^6 + n^3 + 5 \equiv 9 \equiv 2 \pmod 7$$

ដូចនេះ n ចែក នឹង7អោយសំណល់6 មិនយក

ដូចនេះគ្មាន $n \in \{1,2,3....2009\}$ ដែលផ្ទៀងផ្ទាត់ $4n^6 + n^3 + 5$

ចែកដាច់នឹង7ៗ

17. កំណត់គ្រប់គូចំនួនគត់(x,y)ដែល

$$x^2 - y^4 = 2009$$

(Indonesia National Science Olympaid 2009)

សម្រាយ

សមីការអាចសរសេរ

$$(x-y^2)(x+y^2) = 1\times 2009 = 7\times 287 = 49\times 41 = -1\times -2009$$
$$= -7\times -287 = -49\times -41$$

ដោយ $x - y^2 < x + y^2$ យើងបាន

$$\begin{cases} x-y^2 = 1 \\ x+y^2 = 2009 \end{cases}(I) \quad \begin{cases} x-y^2 = 7 \\ x+y^2 = 287 \end{cases}(II) \quad \begin{cases} x-y^2 = 41 \\ x+y^2 = 49 \end{cases}(III)$$

$$\begin{cases} x-y^2 = -2009 \\ x+y^2 = -1 \end{cases}(IV) \quad \begin{cases} x-y^2 = -287 \\ x+y^2 = -7 \end{cases}(V) \quad \begin{cases} x-y^2 = -49 \\ x+y^2 = -41 \end{cases}(VI)$$

បន្ទាប់ពីដោះស្រាយប្រព័ន្ធសមីការខាងលើយើងបានគូចំលើយជា

ចំនួនគត់គឺ $(x, y) \in \{(45,2), (45,-2), (-45,2), (-45,-2)\}$

18. គេអោយa,b,cជាចំនួនគត់វិជ្ជមានៗបើ $30|a+b+c$
ស្រាយបញ្ជាក់ថា $30|a^5+b^5+c^5$
(Indonesia National Science Olympaid 2006)

សម្រាយ

ដំបូងយើងនឹងស្រាយថា $5|x^5-x$

-បើxចែកដាច់នឹង5សំណើរខាងលើពិត

- បើxចែកនឹង5អោយសំណល់1យើងបាន

$x \equiv 1 \pmod 5$

$\Rightarrow x^5 \equiv 1 \pmod 5$

$\Rightarrow x^5 - x \equiv 0 \pmod 5$

សំណើរខាងលើពិត

- បើxចែកនឹង5អោយសំណល់2យើងបាន

$x \equiv 2 \pmod 5$

$\Rightarrow x^5 \equiv 2^5 \equiv 2 \pmod 5$

$\Rightarrow x^5 - x \equiv 0 \pmod 5$

សំណើរខាងលើពិត

- បើxចែកនឹងអោយសំណល់3យើងបាន

$$x \equiv 3 \pmod 5$$

$$\Rightarrow x^5 \equiv 3^5 \equiv 3 \pmod 5$$

$$\Rightarrow x^5 - x \equiv 0 \pmod 5$$

សំណើរពិត

- បើxចែកនឹង5អោយសំណល់3យើងបាន

$$x \equiv 4 \pmod 5$$

$$\Rightarrow x^5 \equiv 4^5 \equiv 3 \pmod 5$$

$$\Rightarrow x^5 - x \equiv 0 \pmod 5$$

សំណើរខាងលើពិត

បន្តមកទៀតយើងនឹងស្រាយ $3 | x^5 - x$

-បើxចែកដាច់នឹង3សំណើរនេះពិត

- បើxចែកនឹង3អោយសំណល់1យើងបាន

$$x \equiv 1 \pmod 3$$

$$\Rightarrow x^5 \equiv 1 \pmod 3$$

$$\Rightarrow x^5 - x \equiv 0 \pmod 3$$

សំណើរនេះពិត

- បើxចែកនឹង3អោយសំណល់ 2 យើងបាន

$$x \equiv 2 \pmod 3$$

$$\Rightarrow x^5 \equiv 32 \equiv 2 \pmod 3$$

$$\Rightarrow x^5 - x \equiv 0 \pmod 3$$

ម្យ៉ាងទៀត x^5 និង x មានភាពគូសេសដូចគ្នានោះ $2|x^5-x$

ដោយ GCD(2,3,5)=1 នោះ $30|x^5-x$ គ្រប់ចំនួនគត់វិជ្ជមាន x ។

យើងបាន

$$\left.\begin{array}{l} 30|a^5-a \\ 30|b^5-b \\ 30|c^5-c \end{array}\right| \Rightarrow 30|a^5+b^5+c^5-(a+b+c)$$

ដោយ a+b+c ចែកដាច់នឹង 30 នោះយើងបាន $30|a^5+b^5+c^5$

19. កំណត់គូចំនួនគត់វិជ្ជមាន (x,y) ដែលផ្ទៀងផ្ទាត់ $\frac{x+y}{x^2-xy+y^2}=\frac{3}{7}$ ។

(Taiwan National Olympaid 2005)

សម្រាយ

Lemma បើ a,b,c,d,e,f ជាចំនួនគត់ដែលផ្ទៀងផ្ទាត់ $a-\frac{b}{c}=\frac{d}{e}$ ដែល GCD(d,e)=1 នោះមានចំនួនគត់ r ដែលផ្ទៀងផ្ទាត់ $\frac{b}{c}=\frac{r}{e}$

សម្រាយ Lemma

តាង d= GCD(b,c) នោះមានចំនួនគត់ n, m ដែល b=nd, c=md និង GCD(n,m)=1 យើងបាន

$$a-\frac{b}{c}=a-\frac{n}{m}=\frac{am-n}{m}=\frac{d}{e}$$

ដោយ GCD(d,e)=1 និងម្យ៉ាងទៀតតាមអាល់កូរីតអឺក្លីតយើងបាន

GCD(am-n,m)=GCD(m,n)=1 នោះ m=e, am-n=d

ដូចនេះ $\frac{b}{c}=\frac{r}{m} \quad (n=r)$

ដូចនេះ **Lemma** នេះពិត

សមីការអាចសរសេរ

$$\frac{x^2-xy+y^2}{x+y}=\frac{7}{3}=x+y-3\frac{xy}{x+y}$$

ដោយ 3 និង 7 ជាចំនួនបឋមរវាងគ្នានោះយើងអាចតាង

$x+y=k, \frac{xy}{x+y}=\frac{l}{9}$ ដែល k និង l ជាចំនួនគត់

សមីការសមមូល

$3k-l=7 \Rightarrow k=2+\frac{l+1}{3} \Rightarrow 3|l+1$ នោះមានចំនួនគត់ v ដែល

$l=3v-1$ យើងបាន

$$k=2+v \Rightarrow \begin{cases} x+y=2+v \\ xy=\frac{(3v-1)(v+2)}{9} \end{cases}$$

នោះមានចំនួនគត់ u ដែល $v+2=9u \Rightarrow v=9u-2$

ព្រោះ 3v-1 ចែកមិនដាច់នឹង 9ៗនោះយើងបាន

$$\begin{cases} x+y=9u \\ xy=27u^2-7u \end{cases}$$

តាមទ្រឹស្តីបទវៀែត x, y ជាឫសសមីការ

$$X^2-9uX+27u^2-7u=0$$

$$\Delta=81u^2-108u^2+28u=-27u^2+28u\geq 0 \Rightarrow u\in\left[0,\frac{28}{27}\right]$$

$$\Rightarrow u=1 \quad (u\in \mathrm{N})$$

ដូចនេះ $(x,y)\in\{\quad(5,4),(4,5)\}$

20. កំណត់ចំនួនពិត(x,y,z)ដែលផ្ទៀងផ្ទាត់ប្រព័ន្ធសមីការ

$$\begin{cases} x = y^3 + y - 8 \\ y = z^3 + z - 8 \\ z = x^3 + x - 8 \end{cases}$$

(Indonesia National Science Olympaid 2007)

សម្រាយ

យើងមាន

$$\begin{cases} x = y^3 + y - 8 & (1) \\ y = z^3 + z - 8 & (2) \\ z = x^3 + x - 8 & (3) \end{cases}$$

ដកអង្គនិងអង្គ(1)និង(2), (2)និង(3), (3)និង(1)យើងបាន

$$\begin{cases} y - z = (z - x)(z^2 + xz + x^2 + 1) \\ z - x = (x - y)(x^2 + xy + y^2 + 1) \\ x - y = (y - z)(y^2 + yz + y^2 + 1) \end{cases}$$

គុណអង្គនិងអង្គយើងបាន

$$(x-y)(y-z)(z-x)\left[1 - (x^2 + xy + y^2 + 1)(y^2 + yz + z^2 + 1)(z^2 + zx + x^2 + 1)\right] = 0$$

តែ $x^2 + xy + y^2$

$\Delta = -3y^2 \le 0 \forall y \in \Re$

$\Rightarrow x^2 + xy + y^2 + 1 \ge 1 \forall x.y \in \Re$

នោះ $\left[1 - (x^2 + xy + y^2 + 1)(y^2 + yz + z^2 + 1)(z^2 + zx + x^2 + 1)\right] \le 0$

-បើ x-y=0 នោះសមីការមានឫស x=y=z=2

-បើ y-z=0 នោះសមីការមានឫស x=y=z=2

-បើ z-x=0 នោះសមីការមានឫស x=y=z=2

សរុបមកសមីការមានចំលើយ (x=2, y=2, z=2)

21.គេអោយចំនួនកុំផ្លិច z_1និង z_2 ដែល $z_1=-1+i$ និង $z_2=2+4i$

រកចំនួនកុំផ្លិចz_3 ដែលអាទិចនៃ z_1 ,z_2 ,z_3 ជាកំពូលទាំង3នៃត្រីសម័ង្សមួយៗ

សម្រាយ

តាង A, B, C ជា អាទិចនៃ z_1 ,z_2 ,z_3 រៀងគ្នាៗយើងបាន

A(-1,1),B(2,4),តាងC(x,y)ៗយើងបាន $AB = 3\sqrt{2}$ និង

$\overrightarrow{AB}(3,3), \overrightarrow{AC}(x+1, y-1)$ នោះ $\overrightarrow{AB}.\overrightarrow{AC} = 3(x+1)+3(y-1)$

តែតាមនិយមន័យ $\overrightarrow{AB}.\overrightarrow{AC} = AB.ABCos60 = 9$ ព្រោះ$AB = AC = 3\sqrt{2}$

តាមទំនាក់ទំនង់ខាងលើយើងបាន $x + y = 3 \quad (1)$

ម្យ៉ាងទៀត $\overrightarrow{BC}(x-2, y-4)$ នោះយើងបាន

$\overrightarrow{CA}.\overrightarrow{CB} = (x-2)(x+1)+(y-1)(y-4) = CA.CB\cos\angle C = 9$

$\Leftrightarrow x^2 + y^2 - x - 5y = 7 \quad (2)$

យើងបានប្រព័ន្ធសមីការ(1)និង(2)បន្ទាប់ពីដោះស្រាយប្រព័ន្ធនេះយើងបាន

ចំលើយ

$$(x,y)\in\left\{\left(\frac{1+3\sqrt{3}}{2},\frac{5-3\sqrt{3}}{2}\right),\left(\frac{1-3\sqrt{3}}{2},\frac{5+3\sqrt{3}}{2}\right)\right\}$$

22. បង្ហាញថា

$$\sum_{n=1}^{9999}\frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)}=9$$

(Proposted by Dr Dorin Andrica)

សម្រាយ

យើងមាន $\frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)}=\frac{\sqrt{n+1}-\sqrt{n}}{\sqrt[4]{n+1}+\sqrt[4]{n}}=\sqrt[4]{n+1}-\sqrt[4]{n}$

នោះ

$$\sum_{n=1}^{9999}\frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)}=\sqrt[4]{10000}-\sqrt[4]{1}=9$$

23. តាងa,b,cជាចំនួនពិតវិជ្ជមានដែលab+bc+ca=1។ ស្រាយបញ្ជាក់ថា

$$\left(a+\frac{1}{b}\right)^2+\left(b+\frac{1}{c}\right)^2+\left(c+\frac{1}{a}\right)^2\geq 16$$

(Proposted By Mircea Becheanu,Bucharest,Romanai)

សម្រាយ

តាមវិសមភាព **AM-GM** និងវិសមភាព **Cauchy-Schwart** យើងមាន

$$\left(a+\frac{1}{b}\right)^2+\left(b+\frac{1}{c}\right)^2+\left(c+\frac{1}{a}\right)^2=a^2+b^2+c^2$$

$$+\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}+2\left(\frac{a}{b}+\frac{b}{c}+\frac{c}{a}\right)$$

$$\geq ab+bc+ca+\frac{1}{ab}+\frac{1}{bc}+\frac{1}{ca}+6\sqrt[3]{\frac{acb}{abc}}$$

$$\geq 7+\frac{3^2}{ab+bc+ca}=16$$

24.មេដ្យានAMនិងកន្លះបន្ទាត់ពុះមុំBNប្រសព្វគ្នាត្រង់P។បន្ទាត់CPប្រសព្វបន្ទាត់ABត្រង់Q។ស្រាយបញ្ជាក់ថាត្រីកោណBNQជាត្រីកោណសមបាត។
(Proposted by Dr Dorin Andrica)

សម្រាយ

តាមទ្រឹស្តីបទ សេវ៉ាយើងមាន

$\frac{AQ}{QB}.\frac{BM}{MC}.\frac{CN}{NA}=1$ តែ $MB=MC$ យើងមាននោះយើងបាន

